**ព្រះរាជសារ**
**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ**
**នរោត្តម សីហមុនី**
**ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា**

ក្នុងឱកាសការបើកបវេសនកាលនៃរដ្ឋសភា សម័យប្រជុំរដ្ឋសភាលើកទី៤
នីតិកាលទី៦ នៅថ្ងៃទី០២ ខែមេសា ឆ្នាំ ២០២០

- សូមក្រាបថ្វាយបង្គំ សម្តេចព្រះមហាសង្ឃរាជទាំងពីរគណៈ ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់
- សូមក្រាបថ្វាយបង្គំ ព្រះថេរានុថេរៈគ្រប់ព្រះអង្គ ជាទីសក្ការៈ
- សម្តេចអគ្គមហាពញាចក្រី ប្រធានរដ្ឋសភា ឯកឧត្តមបណ្ឌិត អនុប្រធានទី១ នៃរដ្ឋសភា លោកជំទាវកិត្តិសង្គហបណ្ឌិត អនុប្រធានទី២នៃរដ្ឋសភា ជាទីស្រឡាញ់រាប់អានដ៏ជ្រាលជ្រៅ
- សម្តេច ឯកឧត្តម លោកជំទាវ សមាជិក សមាជិកានៃរដ្ឋសភាដ៏ឧត្តុង្គឧត្តម
- ឯកឧត្តម លោកជំទាវ ឯកអគ្គរាជទូត ឯកអគ្គរដ្ឋទូត និងភ្ញៀវកិត្តិយសទាំងអស់ ជាទីរាប់អាន
- បងប្អូនជនរួមជាតិទាំងអស់ជាទីស្នេហាដ៏ជ្រាលជ្រៅបំផុត

ទូលព្រះបង្គំ ខ្ញុំព្រះករុណា ខ្ញុំមានសេចក្តីសោមនស្សរីករាយ សូមចូលរួមអបអរសាទរពិធីបើកបវេសនកាលរដ្ឋសភា ដែលប្រារព្ធឡើងក្នុង**សម័យប្រជុំរដ្ឋសភាលើកទី៤ នីតិកាលទី៦ នៅថ្ងៃទី០២ ខែមេសា ឆ្នាំ២០២០** នេះ ។

រដ្ឋសភាដ៏ឧត្តុង្គឧត្តម ក្នុងនាមស្ថាប័ននីតិប្បញ្ញត្តិ បានបំពេញតួនាទីរបស់ខ្លួនយ៉ាងសកម្មប្រកបដោយប្រសិទ្ធភាព ក្នុងនោះរួមមានការអនុវត្តតួនាទីការងារនីតិកម្ម ធ្វើជាតំណាងប្រជាពលរដ្ឋដែលជាម្ចាស់ឆ្នោត និងការងារចុះពិនិត្យតាមដាននូវការអនុវត្តច្បាប់នានា នៅគ្រប់មជ្ឈដ្ឋានសុទ្ធតែបានបំពេញប្រកបដោយភាពជោគជ័យជាច្រើនគួរឲ្យកត់សម្គាល់ ។

ទូលព្រះបង្គំ ខ្ញុំព្រះករុណា ខ្ញុំសូមកោតសរសើរ និងអរគុណដ៏ជ្រាលជ្រៅ ចំពោះ **សម្តេចអគ្គមហាពញាចក្រី ហេង សំរិន** ប្រធានរដ្ឋសភា ឯកឧត្តមបណ្ឌិត អនុប្រធានទី១ នៃរដ្ឋសភា លោកជំទាវកិត្តិសង្គហបណ្ឌិត អនុប្រធានទី២នៃរដ្ឋសភា ឯកឧត្តម លោកជំទាវ

ជាប្រធានគណៈកម្មការ និងសមាជិក សមាជិកានៃរដ្ឋសភាទាំងអស់ ដែលបានខិតខំយកអស់កម្លាំងកាយចិត្ត ក្នុងការពិនិត្យសិក្សាសេចក្តីព្រាងច្បាប់នានា ដើម្បីឲ្យច្បាប់ទាំងនោះពង្រីកសក្តានុពល ប្រសិទ្ធភាពការងារឲ្យទូលំទូលាយ នាយុគសម័យបច្ចុប្បន្ន ។

ជាមួយនេះ រដ្ឋសភាបានប្រឹងប្រែងយ៉ាងសកម្ម ក្នុងការចុះតាមដាននូវសុខទុក្ខ ទទួលយកនូវរាល់បញ្ហាកង្វល់ និងបញ្ហាប្រឈមនានារបស់ប្រជាពលរដ្ឋ ដែលពេលនេះកិច្ចគាំពារសន្តិសុខសង្គមកំពុងត្រូវបានលើកស្ទួយ ក្នុងន័យឲ្យប្រជាពលរដ្ឋទាំងមូលទទួលនូវអត្ថប្រយោជន៍ស្មើៗគ្នា ។

ទូលព្រះបង្គំ ខ្ញុំព្រះករុណា ខ្ញុំសូមកោតសរសើរយ៉ាងក្រៃលែង ចំពោះ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលជាមគ្គុទេសក៍ដឹកនាំប្រទេសប្រកបដោយភាពឈ្លាសវៃ ប្រកាន់ខ្ជាប់នូវគោលនយោបាយជាតិដ៏ត្រឹមត្រូវធានាបានឯករាជ្យ និងអធិបតេយ្យភាពជាតិ គឺជាអ្វីដែលជនរួមជាតិខ្មែរទាំងមូលប្រាថ្នាចង់បានដើម្បីរស់នៅប្រកបដោយភាពស្មើមុខស្មើមាត់ សុខដុមរមនា ស្ថិរភាព និងសន្តិភាពយូរអង្វែង ។ សកម្មភាពមនុស្សធម៌ដ៏ធំធេង និងមិនរើសអើងពូជសាសន៍របស់ **សម្តេច** ប្រមុខរាជរដ្ឋាភិបាលកម្ពុជា គឺជាកាយវិការដ៏ល្អ ប្រពៃបំផុត សម្រាប់ការគោរពពីជនរួមជាតិ និងពិភពលោកទាំងមូល ។

ឆ្លៀតក្នុងឱកាសចូលឆ្នាំថ្មីប្រពៃណីជាតិ ឆ្នាំជូត ទោស័ក ពុទ្ធសករាជ ២៥៦៤ ខាងមុខនេះ ទូលព្រះបង្គំ ខ្ញុំព្រះករុណា ខ្ញុំសូមបួងសួងដល់គុណបុណ្យព្រះរតនត្រ័យ គុណកែវទាំងបី ទេវតារក្សាព្រះមហាស្វេតច្ឆត្រ និងព្រះទសបារមី ព្រមទាំងវត្ថុស័ក្តិសិទ្ធិទាំងអស់ក្នុងលោក សូមតាមបីបាច់ថែរក្សា សម្តេច ឯកឧត្តម លោកជំទាវ និងជនរួមជាតិទាំងអស់ សូមបានប្រកបតែនឹងព្រះពុទ្ធពរគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ និង សូមបួងសួងឲ្យភពផែនដីទាំងមូលចៀសផុតពីជំងឺឆ្លងដ៏កាចសាហាវក្នុងពេលដ៏ខ្លីខាងមុខនេះ ។

នៅទីបញ្ចប់នេះ ទូលព្រះបង្គំ ខ្ញុំព្រះករុណា ខ្ញុំសូមប្រសិទ្ធពរបវរសួស្តីជ័យមង្គលមហាប្រសើរ ជូនសម័យប្រជុំរដ្ឋសភាលើកទី៤ នីតិកាលទី៦ មានសក្តានុពលខ្លាំងក្លាបំពេញតួនាទីភារកិច្ចរបស់ខ្លួន បានប្រកបដោយជោគជ័យយ៉ាងត្រចះត្រចង់ ៕

នរោត្តម សីហមុនី

**នរោត្តម សីហមុនី**